ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយស្តីពី ការវាស់វែងការសិក្សាសិស្ស

## ប្រព័ន្ធសាលារៀនជំនាន់ថ្មីនៅប្រទេសកម្ពុជា





ខែមករា ឆ្នាំ២០២៣

# គោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្ស

## សេចក្តីសង្ខេប

ឯកសារនេះត្រូវបានរៀបចំឡើងដោយប្រព័ន្ធកម្មវិធីសាលារៀនជំនាន់ថ្មីនៃប្រទេសកម្ពុជាក្នុងគោលបំណងបង្ហាញពីរចនាសម្ព័ន្ធទូទៅនៃការវាស់វែងការសិក្សាសិស្សតាមសាលារៀនក្នុងប្រព័ន្ធកម្មវិធីសាលារៀនជំនាន់ថ្មី។ គោលនយោបាយនេះ ក៏បានពណ៌នាផងដែរពីលក្ខណៈវិនិច្ឆ័យក្នុងការសម្រេចចិត្តផ្សេងៗ ទាក់ទងនឹងការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សាសិស្សក្នុងឆ្នាំសិក្សានីមួយៗ។

ការិយាល័យកណ្តាលកម្មវិធីសាលារៀនជំនាន់ថ្មី

ការធ្វើបច្ចុប្បន្នភាពចុងក្រោយ៖ ខែមករា ឆ្នាំ២០២៣

* * * * * * * * * * * * * * * * * *

# ១. សេចក្តីណែនាំ

## ១.១ គោលបំណង

ឯកសារនេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការណែនាំដល់មន្ត្រីអប់រំ អ្នកគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនដែលធ្វើការនៅក្នុងប្រព័ន្ធសាលាជំនាន់ថ្មីពីរបៀបវាយតម្លៃសិស្ស។ ទោះបីជា សាលាជំនាន់ថ្មី (NGS) ជាទូទៅអនុវត្តតាមកម្មវិធីសិក្សាផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា (MOEYS) និង ចូលរួមការប្រឡងមធ្យមសិក្សាបឋមភូមិ (ការប្រឡងឌីប្លូមថ្នាក់ទី៩) និងការប្រឡងមធ្យមសិក្សាទុតិយភូមិ (ការប្រឡងបាក់ឌុបថ្នាក់ទី១២) ក៏ដោយ សាលារៀននៅក្នុងប្រព័ន្ធ NGS អាចផ្លាស់ប្តូរ កម្មវិធីសិក្សា និងមាតិកាប្រឡង ដើម្បីជំរុញសកម្មភាពសិក្សា និងបណ្តុះបំណិនសតវត្សទី២១ ដល់សិស្សានុសិស្សទាំងទិដ្ឋភាពសង្គម និងសេដ្ឋកិច្ច។ ពេលខ្លះ គោលដៅនេះពិបាកសម្រេចបានក្នុងការអនុវត្តជាក់ស្តែង ជាពិសេសនៅពេលដែលការប្រឡងថ្នាក់ជាតិមិនបានវាស់វែងផ្នែកសំខាន់ៗនៃកម្មវិធីសិក្សា NGS ដូចជាជំនាញមន្ទីរពិសោធន៍ សកម្មភាពស្រាវជ្រាវរបស់សិស្ស និងជំនាញបច្ចេកវិទ្យាព័ត៌មាន(ICT)។ ទោះជាយ៉ាងណាក៏ដោយ សាកលវិទ្យាល័យ និងស្ថាប័នក្រោយមធ្យមសិក្សាមួយចំនួន តម្រូវឱ្យមានការវាស់វែងសមត្ថភាពជាក់ស្តែងសិស្សលើសពីលទ្ធផលប្រឡងបាក់ឌុប ឧទាហរណ៍ដូចជាកម្រងស្នាដៃ ការងារគម្រោង...ដែលចូលរួមចំណែកកាត់បន្ថយការផ្តោតអារម្មណ៍ទៅលើតែប្រព័ន្ធប្រឡងថ្នាក់ជាតិមួយមុខ។

គោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្ស ដែលបានបង្ហាញនៅទីនេះ មានគោលបំណងផ្តល់ជាការណែនាំដល់សាលារៀនពីហានិភ័យផ្សេងៗ ទាក់ទងនឹងការវាស់វែងការសិក្សាសិស្ស ដែលនឹងបង្អាក់នូវនវានុវត្តន៍អប់រំផ្សេងៗ ក្នុងដំណើរការរៀន និងបង្រៀន។ ឯកសារនេះ បានបង្ហាញតម្រូវការចាំបាច់សម្រាប់ការវាស់វែងការសិក្សាសិស្សក្នុងទម្រង់ផ្សេងទៀត ហើយវាក៏បានជួយដល់សាលារៀនឱ្យដឹងពីអ្វីដែលហៅថា "ផលជះត្រឡប់" អវិជ្ជមាន បើយើងផ្តោតសំខាន់តែទៅលើលទ្ធផលតេស្ត ដែលជំរុញគ្រូអនុវត្តសកម្មភាព "បង្រៀនសម្រាប់តែការប្រឡង"[1] មួយមុខ ពិសេសក្នុងករណីដែលគណនេយ្យភាពគ្រូបង្រៀន គឺផ្អែកទាំងស្រុង ឬភាគច្រើនតែទៅលើលទ្ធផលតេស្តសិស្ស។ ក្នុងករណីនេះ គ្រូបង្រៀនអាចនឹងបោះបង់ការប្តេជ្ញាចិត្តចំពោះ "ការបង្រៀនពិតប្រាកដ" ឬការបង្រៀនប្រកបដោយភាពច្នៃប្រឌិត ហើយផ្តោតតែលើការជួយសិស្សឱ្យប្រឡងជាប់ ដើម្បីជៀសវាងការស្តីបន្ទោសពីថ្នាក់លើពួកគេ។ ការអនុវត្តរបៀបនេះ គឺជារឿងធម្មតាតែងកើតមាននៅក្នុងប្រព័ន្ធអប់រំតាមបែប "ការបង្រៀនសម្រាប់តែការប្រឡង" ដូចជាប្រទេសកម្ពុជា ដែលផ្តោតសំខាន់លើលទ្ធផលប្រឡង និងចំណាត់ថ្នាក់សិក្សាសិស្ស។ ដោយសារតែបេសកកម្មសំខាន់បំផុតមួយនៃប្រព័ន្ធសាលាជំនាន់ថ្មី គឺលើកកម្ពស់នវានុវត្តន៍អប់រំ និងការអនុវត្តថ្មីក្នុងការបង្រៀន ស្ថានភាពដែលគ្រូ

---

[1] https://en.wikipedia.org/wiki/Washback_effect

បង្រៀនផ្តោតតែលើ "ការបង្រៀនសម្រាប់តែការប្រឡង" នឹងធ្វើឱ្យប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដល់បេសកកម្មនេះ។ ដូចនេះហើយ វាចាំបាច់ណាស់ដែលតម្រូវឱ្យមានវិធានការច្បាស់លាស់ ក្នុងការទប់ស្កាត់ការអនុវត្តបែបនេះក្នុងប្រព័ន្ធកម្មវិធីសាលារៀនជំនាន់ថ្មី។

### ១.២ លក្ខណៈវិវត្តន៍នៃគោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្ស

បរិយាកាសនៃការអនុវត្តនៅក្នុងប្រព័ន្ធសាលាជំនាន់ថ្មីគឺមានលក្ខណៈបត់បែន និងផ្លាស់ប្តូរជានិច្ច។ នេះមានន័យថា គោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្ស មិនគួរមានលក្ខណៈ "នឹងថ្កល់" នោះទេ ប៉ុន្តែគួរតែផ្លាស់ប្តូរ និងបត់បែនតាមបរិបទសិក្សា។ ឧទាហរណ៍ក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញនូវភាពចាំបាច់ក្នុងការកែប្រែការប្រឡងថ្នាក់ជាតិ ទៅតាមរបៀបដែលសិស្សានុសិស្សក្នុងកម្មវិធីសាលារៀនជំនាន់ថ្មីសិក្សា ដែលអាចនាំទៅដល់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬបាក់ឌុបពិសេសមួយសម្រាប់កម្មវិធី។ បើសិនជាមានការប្រែប្រួល ឯកសារនេះត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំផងដែរ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរទាំងនេះ។ ដូច្នេះ គោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្សនៅក្នុងប្រព័ន្ធកម្មវិធី NGS នេះ គួរតែត្រូវបានចាត់ទុកថាជា "ឯកសាររស់" មួយដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពក្នុងកាលកំណត់មួយ។

### ១.៣ ខ្លឹមសារ និងការរៀបចំឯកសារ

គោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្ស ត្រូវបានរៀបចំជា ៤ ផ្នែកដាច់ដោយឡែកពីគ្នា ដែលជួយអ្នកគ្រប់គ្រងសាលា និងគ្រូបង្រៀនឱ្យយល់ដឹងកាន់តែច្បាស់អំពីវចនាសម្ព័ន្ធក្នុងការវាយតម្លៃក្នុងសាលា ចាប់តាំងពីទិដ្ឋភាពរួម ទៅដោយផ្នែក ដែលគ្រប់ភាគីពាក់ព័ន្ធមិនធ្លាប់ដឹងពីមុនមកថាទិដ្ឋភាពនៃការវាយតម្លៃផ្សេងៗ មានទំនាក់ទំនងនឹងគ្នា ដូចជាសកម្មភាពការងារគម្រោងសិស្ស និងការដាក់ពិន្ទុ ។ ដូច្នេះឯកសារត្រូវបានរៀបចំជាផ្នែកៗ ដូចខាងក្រោម៖

- ទស្សនវិជ្ជា និងគោលការណ៍នៃការវាស់វែងការសិក្សាសិស្ស
- ការស្នើឡើងពីការអនុវត្តការវាស់វែងការសិក្សាមួយចំនួន
- ទំនាក់ទំនងរវាងគោលនយោបាយវាស់វែងការសិក្សាសិស្ស និងគោលនយោបាយសំខាន់ៗផ្សេងទៀត
- តួនាទី និងភារកិច្ចអ្នកពាក់ព័ន្ធសាលាក្នុងការអនុវត្តគោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្ស

## ២. ទស្សនវិជ្ជា និងគោលការណ៍ណែនាំសម្រាប់ការវាស់វែងការសិក្សាសិស្ស

### ២.១ ទស្សនវិជ្ជានៅក្នុងប្រព័ន្ធ NGS ទាក់ទងនឹងការវាស់វែងការសិក្សា

គោលដៅក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបង្កើតប្រព័ន្ធសាលារៀនជំនាន់ថ្មី គឺដើម្បីពន្លឿនដំណើរការផ្លាស់ប្តូរប្រព័ន្ធអប់រំកម្ពុជាទៅជាការអប់រំសតវត្សទី២១។ ការអប់រំរបៀបថ្មីនេះ ផ្តោត

សំខាន់ទៅលើការផ្ដល់ឱកាសឱ្យសិស្សអនុវត្តជាក់ស្ដែងនូវអ្វីដែលពួកគេរៀន ជាជាងការទន្ទេញចាំមាត់នូវអ្វីៗដែលមានក្នុងសៀវភៅសិក្សា។ តារាងខាងក្រោមបានសង្ខេបនូវភាពខុសគ្នា មួយចំនួនរវាងប្រព័ន្ធអប់រំសតវត្សទី២០ និង ២១ និងរបៀបដែលប្រព័ន្ធនេះមានឥទ្ធិពលទៅលើទស្សនវិជ្ជានៃការវាស់វែងការសិក្សាសិស្សក្នុងកម្មវិធីសាលាជំនាន់ថ្មី។

*តារាង ២.១៖ ការប្រៀបធៀបរវាង ប្រព័ន្ធអប់រំសតវត្សទី ២០ និង ២១*

| កត្តាប្រៀបធៀប | សតវត្សទី ២០ | សតវត្សទី ២១ |
|---|---|---|
| បញ្ញត្តិនៃការរៀន | • ការផ្ទេរព័ត៌មាន<br>• ការរៀនបែបអកម្ម | • ឱ្យសិស្សចេះរៀនដោយខ្លួនឯង<br>• ការរៀនបែបសកម្ម |
| កម្មវិធីសិក្សា | • ការកំណត់ស្តង់ដា<br>• ការប្រើប្រាស់សៀវភៅសិក្សាគោលជាធំ | • ការកំណត់តាមបុគ្គល<br>• ការផ្តោតទៅលើការស្រាវជ្រាវ |
| ការវាស់វែងការសិក្សា | • ការផ្តោតទៅលើការធ្វើតេស្ត<br>• ការផ្តោតលើការគិតកម្រិតទាប | • ការផ្តោតទៅលើគម្រោងសិក្សា ឬកម្រងស្នាដៃសិស្ស<br>• ការផ្តោតលើការគិតកម្រិតខ្ពស់ |
| ទស្សនវិជ្ជាអប់រំ | • អនុលោមភាព<br>• ភាពស្រប/ដូចគ្នា<br>• ឯកសណ្ឋាន | • ឌីណាមិក (រស់រវើក)<br>• មិនដូចគ្នា<br>• ការច្នៃប្រឌិត |

តាមរយៈតារាងនេះ បានបង្ហាញថាការធ្វើតេស្តសិស្សតាមទម្លាប់ពីមុន មិនមែនជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការជំរុញការរៀនបែបសកម្ម ឬការគិតកម្រិតខ្ពស់ដល់សិស្សបានទេ ព្រោះតែការលំបាកក្នុងការបង្កើតសំណួរដើម្បីវាស់វែងបំណិនគិតកម្រិតខ្ពស់ដូចជាកម្រិតវាយតម្លៃ ឬបង្កើតថ្មី។ អាស្រ័យហេតុនេះហើយបានជាក្នុងប្រព័ន្ធកម្មវិធីសាលារៀនជំនាន់ថ្មី ទស្សនវិជ្ជាក្នុងការវាស់វែងការសិក្សាសិស្សគឺប្រើប្រាស់ឧបករណ៍ផ្សេងៗទៀតដូចជា កម្រងស្នាដៃសិស្ស ការងារគម្រោង ការតាំងពិព័រណ៍ ការជជែកដេញដោល សកម្មភាពក្លឹបសិក្សា និងការប្រើប្រាស់ផលិតផលច្នៃប្រឌិតផ្សេងៗ បន្ថែមទៅលើការធ្វើតេស្តតាមបែបប្រពៃណី ដែលប្រើតែក្រដាស និងប៊ិក ជាដើម។

## ២.២ ជំនឿសំខាន់ៗរបស់អ្នកអប់រំក្នុងកម្មវិធី NGS ទាក់ទងនឹងការវាស់វែងការសិក្សាសិស្ស

ទស្សនវិជ្ជាវាស់វែងការសិក្សាសិស្សនៅក្នុងប្រព័ន្ធសាលាជំនាន់ថ្មី ត្រូវបានបង្កើតឡើងផ្អែកលើបណ្តុំគំនិតសំខាន់ៗ មួយចំនួនដែលឆ្លុះបញ្ចាំងពីជំនឿនៃការជួយសិស្សក្នុងការសិក្សា។ គំនិតទាំងនេះរួមមាន ដូចខាងក្រោម៖

### គំនិតទី ១៖ ការវាស់វែងការសិក្សាសិស្សដោយប្រើវិធីចម្រុះ

អ្នកអប់រំក្នុងប្រព័ន្ធសាលារៀនជំនាន់ថ្មី ជឿជាក់លើការវាស់វែងការសិក្សាដោយប្រើវិធីចម្រុះ ដោយមានតុល្យភាពរវាងការវាយតម្លៃបែបដំណាក់ និងការវាយតម្លៃបែបសរុប រួមទាំងបច្ចេកទេសប្រមូលទិន្នន័យវាស់វែងផ្សេងៗ ដូចជាសំណួរមិនលម្អៀង សំណួរលម្អៀង (ដូចជាតែងសេចក្តី) ការងារគម្រោង កម្រងស្នាដៃសិស្ស ជាដើម។ល។

### គំនិតទី ២៖ សារៈសំខាន់នៃការបង្កើតកំហុស

អ្នកអប់រំក្នុងប្រព័ន្ធសាលារៀនជំនាន់ថ្មី ជឿថាការបង្កើតកំហុស មានសារៈសំខាន់ណាស់សម្រាប់ការរៀនសូត្រ។ មានន័យថា មនុស្សតែងតែរៀនពីកំហុស។ ដូច្នេះហើយ គេមិនត្រូវមើលងាយ ឬស្តីបន្ទោសចំពោះកំហុសដែលសិស្សបានបង្កើតនោះទេ ប៉ុន្តែគ្រូបង្រៀនគួរប្រើកំហុសជា "ឱកាស" ដើម្បីកែលម្អការរៀនសូត្រ។

### គំនិតទី ៣៖ តួនាទីនៃការផ្តល់មតិត្រឡប់បែបស្ថាបនា

អ្នកអប់រំក្នុងប្រព័ន្ធសាលារៀនជំនាន់ថ្មី ជឿថាមតិត្រឡប់បែបស្ថាបនាគឺសំខាន់ជាង "ពិន្ទុ" ។ ទោះជាការវាស់វែងការសិក្សាត្រូវបានធ្វើឡើងក្នុងទម្រង់ណាមួយក៏ដោយ គ្រូបង្រៀនគួរប្រើប្រាស់ដំណើរការវាស់វែងការសិក្សាជាឱកាស ដើម្បីផ្តល់មតិត្រឡប់បែបស្ថាបនាដល់សិស្ស ជាជាងគ្រាន់តែកត់ត្រាពិន្ទុចូលក្នុងបញ្ជីពិន្ទុរបស់សិស្ស។ គ្រូបង្រៀនមិនគួររិះគន់សិស្សដែលរៀនយឺតមិនទាន់គេ ហើយគួរផ្តល់ការលើកទឹកចិត្ត និងការសរសើរដល់សិស្សដែលធ្វើបានលទ្ធផលល្អ។

### គំនិតទី ៤៖ ការវាស់វែងការសិក្សាគឺជា "មធ្យោបាយ" នាំទៅដល់ "ទីចុងបញ្ចប់"

អ្នកអប់រំក្នុងប្រព័ន្ធសាលារៀនជំនាន់ថ្មី ជឿថា "ការវាស់វែងការសិក្សា" គឺជាមធ្យោបាយមួយដែលនាំទៅដល់ទីបញ្ចប់ដែល "ទីចុងបញ្ចប់" នេះមានន័យថាគ្រូបង្រៀនមានការយល់ដឹងកាន់តែប្រសើរពីចំណេះដឹងដែលសិស្សទទួលបាន និងចំណុចផ្សេងៗដែលត្រូវកែលម្អសម្រាប់ការបង្រៀនលើកក្រោយ។ គ្រូបង្រៀនមិនគួរមើលឃើញថាការធ្វើតេស្តគឺជា "ទីចុងបញ្ចប់" ដែលត្រូវបញ្ចប់អ្វីៗត្រឹមតេស្តនេះ ហើយផ្តោតខ្លាំងតែទៅលើសកម្មភាពបង្រៀនដែលមានលក្ខណៈ "បង្រៀនសម្រាប់តែការប្រឡង" នោះទេ។

### គំនិតទី ៥៖ ការកាត់បន្ថយជាអប្បបរមានូវការវាស់វែងការសិក្សាដែលមានលក្ខណៈប្រកួតប្រជែង

អ្នកអប់រំក្នុងប្រព័ន្ធសាលាជំនាន់ថ្មី ជឿជាក់ថាយើងគួរដាក់ការខិតខំទៅលើដំណើរការវាស់វែងការសិក្សាដែលអាចជួយលើចំណុចខ្វះខាតសិស្សតាមដែលអាចធ្វើទៅបាន។ ការវាស់វែងការសិក្សាសិស្សត្រូវបានគេមើលឃើញថាជាដំណើរការនៃការប្រកួតប្រជែងមួយដែលសិស្សម្នាក់ៗប្រៀបធៀបខ្លួនពួកគេទៅសិស្សដទៃទៀត។ សម្រាប់សិស្សទទួលលទ្ធផលមិនសូវល្អ ការធ្វើបែបនេះនឹងធ្វើឱ្យពួកគេបាក់ទឹកចិត្ត និងមិនចង់ចូលរួមក្នុងដំណើរការសិក្សាផ្សេងៗ ។ ក្នុងករណីធ្ងន់ធ្ងរជាងនេះ សិស្សទាំង

នោះនឹងត្រូវបានគេ "ដាក់ស្លាក" ថាជាសិស្សរៀនមិនពូកែ ឬអន់ ដែលអាចឈានទៅដល់អ្វីដែលគេឱ្យឈ្មោះថា "ទំនាយដោយខ្លួនឯងថាធ្វើមិនកើត" ។ ហេតុដូចនេះហើយ គ្រូបង្រៀនគួរកមធ្យោបាយផ្សេងៗ ដើម្បីធានាថាជោគជ័យសិស្សម្នាក់ក្នុងថ្នាក់មិនមែនបានមកពីបរាជ័យសិស្សដទៃទៀតនោះទេ។ សូមធ្វើការសរសើរ និងលើកទឹកចិត្តសិស្សដែលទទួលបានលទ្ធផលល្អ និងជួយផ្តល់មតិត្រឡប់ស្ថាបនាទៅដល់សិស្សណាធ្វើមិនសូវបានលទ្ធផលល្អ។ ដូចនេះហើយបានជាប្រព័ន្ធ NGS មិនលើកទឹកចិត្តឱ្យអនុវត្តនូវរបៀបបង្រៀនបែប "ការដាក់ស្លាកសិស្ស" និង "ប្រព័ន្ធនៃការដាក់ចំណាត់ថ្នាក់សិស្ស" ។

ជាថ្មីម្តងទៀត យើងកត់សម្គាល់ឃើញថាគំនិតផ្សេងៗ ដែលបានរៀបរាប់ខាងលើមិនមានលក្ខណៈនឹងថ្កល់ឬមិនប្រែប្រួលនោះទេ ប៉ុន្តែអាចប្រែប្រួល និងផ្លាស់ប្តូរនៅពេលដែលប្រព័ន្ធ NGS មានការវិវឌ្ឍ ដែលអាចនាំទៅដល់ការពង្រីក ឬកែប្រែគំនិតនីមួយៗ ក៏ដូចជាការបន្ថែមគំនិតថ្មីៗទៀត។

## ៣. អនុសាសន៍សម្រាប់ការវាស់វែងការសិក្សាសិស្ស

### ៣.១ ការប្រើប្រាស់ការវាយតម្លៃបែបដំណាក់ និងបែបសរុប និងការស្គាល់ពីភាពខុសគ្នា

ប្រព័ន្ធកម្មវិធីសាលារៀនជំនាន់ថ្មី រំពឹងថាសាលាទាំងអស់នឹងមានតុល្យភាពរវាងការវាយតម្លៃបែបដំណាក់ និងការវាយតម្លៃបែបសរុប ហើយយល់ពីភាពខុសគ្នា និងគោលបំណងនៃការវាយតម្លៃទាំងពីរប្រភេទនេះ។ ការវាស់វែងទាំងពីរនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ការវាស់វែងបែបដំណាក់** ជាដំណើរការនៃការប្រមូលព័ត៌មាន ការវិភាគ ការបកស្រាយ និងការប្រើប្រាស់ភស្តុតាងដើម្បីកែលម្អការសិក្សាសិស្ស និងជួយឱ្យសម្រេចបាននូវសក្តានុពលពួកគេ។ ការវាស់វែងបែបដំណាក់ ភាគច្រើនប្រើប្រាស់ប្រភេទសំណួរដែលអាចឱ្យគ្រូយល់ពីរបៀបសិស្សប្រើក្នុងការដោះស្រាយ ដែលមានសារៈប្រយោជន៍ជាខ្លាំងក្នុងការបង្រៀនបំប៉នលើកក្រោយ ។ ការវាស់វែងបែបដំណាក់ ជាផ្នែកសំខាន់មួយក្នុងការអនុវត្តក្នុងថ្នាក់រៀន ហើយត្រូវប្រែបាច់បញ្ចូលទៅក្នុងកម្មវិធីសិក្សា។ គោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្សបានចែងច្បាស់ពីការវាស់វែងបែបដំណាក់ ដើម្បីឱ្យគ្រប់ភាគីពាក់ព័ន្ធដឹងថាអ្វីជាការវាស់វែងប្រភេទនេះ និងរបៀបដែលត្រូវអនុវត្តក្នុងសាលារៀន។ បន្ថែមពីនេះទៀត ការវាស់វែងបែបដំណាក់មិនគួរយកពិន្ទុ ហើយដាក់បញ្ចូលទៅក្នុងការសម្រេចចិត្តឱ្យសិស្សជាប់ ឬធ្លាក់ថ្នាក់នោះទេ[2] ។ ការវាស់វែងបែបដំណាក់គួរធ្វើជាប្រចាំ និងញឹកញាប់ ដើម្បីឱ្យគ្រូបង្រៀនអាចឆ្លុះបញ្ចាំងទៅលើការបង្រៀន និងចំណុចត្រូវកែប្រែសម្រាប់ការបង្រៀនលើកក្រោយ។

**ការវាស់វែងបែបសរុប** ជាការវាស់វែងដែលគេធ្វើឡើងនៅ "ចុងគ្រា" ដើម្បីវាស់ស្ទង់កម្រិតយល់ដឹងសិស្សទៅនឹងលក្ខណៈវិនិច្ឆ័យក្នុងកម្មវិធីសិក្សា ហើយសម្រេចថាសិស្សនោះអាចជាប់ ឬធ្លាក់ថ្នាក់ ។ គ្រូបង្រៀនត្រូវយល់ឱ្យបានច្បាស់ពីគោលការណ៍ និងការអនុវត្តរបស់ប្រព័ន្ធអប់រំក្នុងការវាស់វែងបែបសរុបរបៀបនេះ ដូចជាការប្រឡងប្រចាំខែ ការប្រឡងឆមាសជាដើម។ ការវាស់វែងបែបសរុប ជាទូទៅប្រើប្រាស់ប្រភេទសំណួរមិនលម្អៀង (ដូចជាសំណួរពហុជ្រើសរើស) ដែលវាផ្ទុយទាំងស្រុងពីការវាស់វែងបែបដំណាក់ដែលផ្តោតទៅលើដំណើរការ ដែលសិស្សដោះស្រាយបញ្ហាដូចបានរៀបរាប់ខាងលើ ។[3]

### ៣.២ ការធ្វើចំណាត់ថ្នាក់សិស្ស និងការដាក់ពិន្ទុ

**ប្រព័ន្ធដាក់ពិន្ទុ៖** ប្រព័ន្ធដាក់ពិន្ទុនៅក្នុងសាលាជំនាន់ថ្មីប្រើប្រព័ន្ធដាក់ពិន្ទុបែបលក្ខណៈវិនិច្ឆ័យ (Criterion-reference) ដោយប្រើមាត្រដ្ឋានពិន្ទុពី ១ ដល់ ១០ ដែលមានចែងក្នុងគោលការណ៍

---

[2]Adapted from: http://mics.edu.gh/Guidelines%20for%20developing%20a%20school%20assessment%20policy%20in%20the%20Diploma%20Programme.pdf

[3]Ibid.

ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់ពិន្ទុ ៥ ជាពិន្ទុទាបបំផុតសិស្សធ្វើបានដើម្បីប្រឡងជាប់។ ប្រព័ន្ធដាក់ពិន្ទុបែបចំណាត់ថ្នាក់ (Norm-reference) និងការធ្វើចំណាត់ថ្នាក់សិស្សមិនត្រូវបានលើកទឹកចិត្តឱ្យប្រើក្នុងប្រព័ន្ធកម្មវិធីសាលារៀនជំនាន់ថ្មីទេ លើកលែងតែក្នុងករណីដែលគ្រូបង្រៀនយល់ថាពិន្ទុតេស្តត្រូវដាក់ពិន្ទុឡើងវិញតាម "ខ្សែកោង" ប៉ុណ្ណោះ។ គោលការណ៍ណែនាំក្នុងការដាក់ពិន្ទុតាមខ្សែកោងមានពន្យល់ក្នុងឯកសារ *សៀវភៅណែនាំស្តីពីការវាស់វែងការសិក្សាសិស្សនៃកម្មវិធីសាលារៀនជំនាន់ថ្មី*។[4]

**ការប្រើប្រាស់និទ្ទេសបទ (Rubrics)៖** កម្មវិធីបានណែនាំឱ្យគ្រូបង្រៀនបង្កើតនិទ្ទេសបទផ្សេងៗ ដើម្បីវិនិច្ឆ័យសកម្មភាពផ្សេងៗដូចជា ការជជែកដេញដោល ការធ្វើបទបង្ហាញ ការប្រកួតប្រជែង និងផលិតផលច្នៃប្រឌិតផ្សេងៗ ដើម្បីពង្រឹងភាពជឿជាក់នៃការដាក់ពិន្ទុរវាងគ្រូបង្រៀន និងគណៈកម្មការវាយតម្លៃដែលកំពុងធ្វើការវិនិច្ឆ័យ។

**ភាពបត់បែនក្នុងការដាក់ពិន្ទុ៖** សាលារៀននីមួយៗ នៅក្នុងប្រព័ន្ធ NGS មានសេរីភាពច្រើនទាក់ទងនឹងរបៀបដែលពួកគេអនុវត្តគោលការណ៍ណែនាំ និងវាយតម្លៃសិស្សដែលមាននៅក្នុងឯកសារនេះ។ ជាឧទាហរណ៍ គ្រូបង្រៀនខ្លះអាចឱ្យតម្លៃទៅលើភាពត្រឹមត្រូវនៃការអនុវត្តបង្ហាញសមត្ថភាពរបស់សិស្ស ជាជាងទៅលើចំណាត់ថ្នាក់ដែលពួកគេទទួលបានអំឡុងពេលធ្វើបាយការណ៍។ ករណីមានការប្រែប្រួលច្រើន គ្រូគួរពិភាក្សាជាមួយថ្នាក់លើជាបន្ទាន់ (ឧទាហរណ៍ គ្រូប្រឹក្សាគរុកោសល្យ ឬនាយករង)។ គ្រូបង្រៀនក៏អាចជំនួសការធ្វើតេស្តប្រចាំខែ ដោយការវាស់វែងផ្សេងៗទៀតដែលមិនមែនជាតេស្ត (សូមមើលខាងក្រោម)។

## ៣.៣ ឧបករណ៍វាស់វែងការសិក្សាសិស្ស

**ការប្រើប្រាស់តេស្តសំណេរ៖** ការធ្វើតេស្តសំណេរគួរតែត្រូវបានកំណត់ចំនួន ព្រោះតេស្តប្រភេទនេះ វាយតម្លៃបំណិនគិតកម្រិតខ្ពស់ ហើយគួរប្រើតែក្នុងករណីដែលជៀសវាងមិនបានដូចជាការប្រឡងឆមាសទូទាំងសាលាជាដើម។ ពេលបង្កើតតេស្ត គ្រូបង្រៀនគួរអនុវត្តតាមគោលការណ៍ណែនាំអនុវត្តដែលមានចែងក្នុង *សៀវភៅណែនាំស្តីពីការវាស់វែងការសិក្សាសិស្ស របស់NGS*។ [5] គួរកត់សម្គាល់ផងដែរថា សំណួរតេស្តមិនលម្អៀង (ឧទាហរណ៍៖ សំណួរពហុជ្រើសរើស) ត្រូវបានប្រើដើម្បីវាយតម្លៃបំណិន ការគិតកម្រិតទាប (កម្រិតចងចាំ កម្រិតយល់ដឹង និងកម្រិតអនុវត្តន៍) ខណៈពេលដែលការប្រើប្រាស់តេស្តប្រភេទតែងសេចក្តី និងសំណួរលម្អៀងផ្សេងទៀតគឺប្រើប្រាស់សម្រាប់វាស់បំណិនគិតកម្រិតខ្ពស់ (កម្រិតវិភាគ កម្រិតវាយតម្លៃ និងកម្រិតបង្កើតថ្មី)។ ការអនុវត្តបែបនេះទើបអាចបង្កើនសុពលភាពខ្លឹមសារ និងសុពលភាពបំណិននៃតេស្តសំណេរបាន។

---

[4] http://www.kapekh.org/files/report_file/350-en.pdf ( cf. p. 16)
[5] Ibid.

ការបែងចែកចំនួនពិន្ទុដ៏សមស្របមួយរវាងសំណួរមិនលម្អៀង និងសំណួរលម្អៀង គួរអនុវត្តតាមគោលការណ៍ ៨០-២០ (សំណួរមិនលម្អៀង ៨០% និងសំណួរលម្អៀង ២០%)។

**តេស្តនៅផ្ទះ៖** ក្នុងអំឡុងពេលវាយតម្លៃ ដើម្បីលើកទឹកចិត្តដល់សកម្មភាពស្រាវជ្រាវ និងការគិត ប្រកបដោយភាពច្នៃប្រឌិត គ្រូបង្រៀនក៏ត្រូវបានលើកទឹកចិត្តឱ្យផ្តល់ *"តេស្តនៅផ្ទះ"*[6] ផងដែរទៅឱ្យសិស្សដើម្បីអនុវត្តនូវអ្វីដែលសិស្សបានរៀននៅសាលា គួបផ្សំនឹងការស្រាវជ្រាវខាងក្រៅ ដើម្បីឆ្លើយសំណួរក្រៅមេរៀន។ តេស្តនៅផ្ទះ ជួយជំរុញសកម្មភាពស្រាវជ្រាវសិស្ស ដែលចាំបាច់ជាខ្លាំងក្នុងទស្សនវិជ្ជានៃការបង្រៀន និងរៀនក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី។

**ការវាស់វែងការសិក្សាសិស្សដោយមិនប្រើតេស្ត៖** ការប្រើប្រាស់ទម្រង់ផ្សេងៗនៃការវាស់វែងការសិក្សាដោយមិនប្រើតេស្តមានដូចជា ការងារគម្រោង ការងារពិសោធន៍ ការតាំងពិព័រណ៍ ការងារក្លឹបសិក្សា ការជជែកដេញដោល ការធ្វើបទបង្ហាញជាវីដេអូ និងទម្រង់ផ្សេងៗទៀត ត្រូវបានលើកទឹកចិត្ត។ នៅពេលប្រើប្រាស់ទម្រង់វាស់វែងការសិក្សាទាំងអស់នេះ យើងអាចប្រើប្រាស់ប្រព័ន្ធផ្តល់ពិន្ទុពី ១ ដល់ ១០ ដែលបានបរិយាយខាងលើផងដែរ ។ ក្នុងករណីការងារគម្រោងសិក្សា ដែលត្រូវបានចាត់ទុកជាទម្រង់នៃការវាស់វែងការសិក្សាដោយមិនប្រើតេស្តដ៏សំខាន់បំផុតមួយនោះ គ្រូបង្រៀនគួរអនុវត្តតាម *សៀវភៅណែនាំស្តីពីការសិក្សាបែបស្ថាបនានិយម របស់ NGS* ដើម្បីវាយតម្លៃការងារគម្រោងទាំងអស់នោះ។[7]

## ៣.៤ ការប្រើប្រាស់ធនាគារសំណួរ

សាលារៀនទាំងអស់ គួរចាត់ទុកសំណួរតេស្តជាទ្រព្យសម្បត្តិរបស់សាលាដែលគួរតែបង្កើត និងអភិវឌ្ឍជាប្រចាំ។ ផ្ទុយពីសាលារៀនសាធារណៈផ្សេងៗ សាលាក្នុងកម្មវិធីសាលារៀនជំនាន់ថ្មីបានបង្កើតសំណួរតេស្តសម្រាប់ការប្រឡង វិភាគសំណួរតេស្ត និងប្រមូលទុកសំណួរតេស្តល្អៗ ក្នុងប្រព័ន្ធ NGS និងកែលម្អបន្ថែមទុកប្រើប្រាស់នាពេលអនាគត។ កន្លែងដែលប្រមូល និងស្តុកទុកសំណួរតេស្តទាំងអស់នេះហៅថា ធនាគារសំណួរ ដែលផ្តល់លទ្ធភាពឱ្យសាលាទាំងអស់ក្នុងប្រព័ន្ធអាចចូលទៅប្រើប្រាស់ និងទាញយកបានពីវេបសាយរបស់កម្មវិធីសាលារៀនជំនាន់ថ្មី (www.ngs.edu.kh)។

## ៣.៥ ការកត់ត្រា និងការធ្វើរបាយការណ៍លទ្ធផលនៃការវាស់វែងការសិក្សា

**ការកត់ត្រាលទ្ធផលវាស់វែងការសិក្សាសិស្ស៖** ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ឱ្យសាលារៀននូវ សៀវភៅបញ្ជីពិន្ទុសម្រាប់កត់ត្រាលទ្ធផលពិន្ទុបានពីការវាស់វែងការសិក្សាសិស្ស។ គំរូកំណត់ត្រាទាំងនេះ ត្រូវបានប្រើប្រាស់ដោយសាលារៀនទាំងអស់។ ទោះជាបែបនេះក៏ដោយ សាលា

[6] https://www.trentu.ca/academicskills/how-guides/how-study/prepare-and-write-exams/preparing-and-writing-take-home-exam

[7] http://www.kapekh.org/files/report_file/99-en.pdf (Cf. p. 24).

រៀនគួរកត់ត្រាទិន្នន័យពិន្ទុបានពីការវាយតម្លៃបែបជំណាក់ ដាច់ដោយឡែកពីពិន្ទុបានពីការវាយតម្លៃបែបសរុប ដើម្បីជៀសវាងការច្រឡំគ្នា ដែលជាពិន្ទុសម្រាប់សម្រេចឱ្យសិស្សឡើង ឬរៀនត្រួតថ្នាក់។

**ការធ្វើរបាយការណ៍លទ្ធផលវាស់វែងការសិក្សាសិស្ស៖** លទ្ធផលសិក្សាសិស្សគួរត្រូវបានរាយការណ៍ជូនមាតាបិតាជារៀងរាល់ខែ ដោយប្រើទម្រង់របាយការណ៍ស្តង់ដាដែលអនុម័តដោយ ក្រសួងអប់រំ យុវជន និងកីឡា ។ ការពិភាក្សាជាមួយមាតាបិតាអំពីការអនុវត្តរបស់កូនៗពួកគេគួរតែត្រូវបានរៀបចំជាទៀងទាត់ដោយ សាលារៀនយ៉ាងហោចណាស់ ២ ដងក្នុងមួយឆ្នាំ ហើយអាចធ្វើទាំងជំនួបជាបុគ្គល និងការប្រជុំក្រុមធំកម្រិតសាលា ។ ការជួបជាមួយមាតាបិតាលក្ខណៈបុគ្គលមានសារៈសំខាន់ណាស់ ជាពិសេសក្នុងករណីសិស្ស ជួបការលំបាក។

## ៣.៦ ការរៀបចំសិស្សសម្រាប់ការប្រឡងដែលតម្រូវឱ្យមានគណនេយ្យភាពខ្ពស់ (High Stake Examination)

ប្រព័ន្ធសាលារៀនជំនាន់ថ្មី មិនអនុញ្ញាតឱ្យគ្រូបង្រៀនរៀបចំថ្នាក់ឯកជន ឬការបង្រៀនក្រៅម៉ោងសម្រាប់សិស្សត្រៀមប្រឡងនានា មិនថាតេស្តធ្វើឡើងក្នុងសាលា ឬការធ្វើតេស្តខាងក្រៅដែលគ្រប់គ្រងដោយក្រសួង អប់រំ យុវជន និងកីឡា (ឧទាហរណ៍ ការប្រឡងបាក់ឌុប) នោះឡើយ។ ទោះជាយ៉ាងនេះក៏ដោយ សាលារៀនអាចរៀបចំការបំប៉នបន្ថែមសម្រាប់សិស្សដែលមានតម្រូវការពិសេស ដូចជាសិស្សដែលរៀនមិនទាន់គេ។ ក្នុងករណីនេះ សាលារៀនអាចរៀបចំគ្រូបង្រៀនខាងក្នុង ឬខាងក្រៅដែលមានសមត្ថភាព មកផ្តល់ការបំប៉នដោយប្រើប្រាស់ថវិកាផ្ទៃក្នុងបានពីថវិកាបង់ប្រចាំឆ្នាំពីអាណាព្យាបាល។ ថវិកាចំណាយទៅលើការបំប៉នសិស្ស មិនត្រូវយកផ្ទាល់ពីសិស្សនោះឡើយ ជាពិសេសសិស្សដែលមកពីគ្រួសារក្រីក្រ។

## ៣.៧ ការប្រើប្រាស់តេស្តអេឡិចត្រូនិក

សាលាជំនាន់ថ្មីកំពុងផ្លាស់ប្តូរការប្រឡងទៅជាទម្រង់អេឡិចត្រូនិច ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសាលារៀនដែលមានឈ្មោះថា NGS Mobile។ ប្រព័ន្ធនេះ មានមុខងារច្រើន រួមបញ្ចូលទាំងការប្រឡងតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។ ការធ្វើតេស្តតាមបែបអេឡិចត្រូនិកបែបនេះមានអត្ថប្រយោជន៍ជាច្រើន រួមមាន៖

- **មិនប៉ះពាល់ដល់បរិស្ថាន៖** អត្ថប្រយោជន៍ដ៏ធំបំផុតមួយនៃការប្រឡងតាមអ៊ីនធឺណិត គឺជាការជួយបរិស្ថានដោយប្រយោល ព្រោះវាកាត់បន្ថយការប្រើប្រាស់ក្រដាសក្នុងដំណើរការប្រឡង។
- **សន្សំថវិកា៖** ការប្រឡងតាមអ៊ីនធឺណិតក៏ជួយផងដែរក្នុងការសន្សំសំចៃថវិកាដោយជួយសាលាកាត់បន្ថយការចំណាយលើការទិញក្រដាស និងទឹកថ្នាំសម្រាប់បោះពុម្ព ក៏ដូចជាថវិកាសម្រាប់អនុរក្សក្នុងដំណើរការប្រឡងផងដែរ ។

- **សន្សំពេលវេលា៖** ការប្រឡងតាមអ៊ីនធឺណិតជួយសន្សំសំចៃពេលវេលា ដែលត្រូវការសម្រាប់ការកែកិច្ចការប្រឡង និងការបញ្ចូលពិន្ទុ។
- **កាន់តែមានសុវត្ថិភាព និងកាត់បន្ថយការលួចចម្លងពេលប្រឡង៖** តាមរយៈការច្របល់សំណួរអំឡុងពេលប្រឡង ការប្រឡងតាមអ៊ីនធឺណិតកាត់បន្ថយឱកាសដែលក្មេងលួចមើលឬចម្លងឯកសារ ដែលធ្វើឱ្យលទ្ធផលតេស្តកាន់តែមានភាពទុកចិត្តបាន ។
- **ភាពងាយស្រួល៖** ការប្រឡងតាមអ៊ីនធឺណិតមានភាពងាយស្រួលក្នុងការរៀបចំ និងរក្សាទុកសំណួរតេស្តល្អៗ ងាយស្រួលជាងការប្រើប្រាស់កម្លាំងមនុស្សក្នុងការគ្រប់គ្រងចាត់ចែង។

ដោយមើលឃើញពីចំណុចទាំងអស់ខាងលើ សាលាជំនាន់ថ្មីរំពឹងថានឹងផ្លាស់ប្តូរទៅប្រើប្រាស់ការធ្វើតេស្តតាមប្រព័ន្ធអេឡិចត្រូនិកនៅគ្រប់សាលារៀនដែលមានលទ្ធភាពធ្វើបាន។

## ៣.៨ ការប្រឡងចូលរៀន

ដោយសារស្តង់ដាអភិបាលកិច្ចខ្ពស់ ដែលបង្ហាញដោយសាលាជំនាន់ថ្មី ជាហេតុនាំឱ្យមានតម្រូវការចូលរៀនកាន់តែខ្ពស់ពីសំណាក់សិស្សានុសិស្ស។ តម្រូវការកាន់តែខ្ពស់នេះ ជាបញ្ហាប្រឈមមួយផងដែរសម្រាប់សាលារៀនក្នុងកម្មវិធី ព្រោះសាលាត្រូវរក្សាផលធៀបសិស្ស-ថ្នាក់រៀនតែ ៣៦ នាក់ប៉ុណ្ណោះក្នុង ១ ថ្នាក់ដើម្បីទទួលបានការវាយតម្លៃទទួលស្គាល់គុណភាពជាសាលារៀនជំនាន់ថ្មី ។ មួយវិញទៀត អនក្ខរកម្មជាបញ្ហាប្រឈមក្នុងប្រព័ន្ធអប់រំ (សម្រាប់សិស្សដែលចេញពីកម្រិតបឋមសិក្សាឆ្លងចូលកម្រិតអនុវិទ្យាល័យ និងពីអនុវិទ្យាល័យទៅវិទ្យាល័យ) ដោយសិស្សដែលមិនចេះអានអក្សរ និងគិតលេខ មិនអាចទទួលបានការអប់រំពេញលេញជាមួយនឹងសម្ភារៈរូបវន្តទំនើបៗនៅក្នុងប្រព័ន្ធសាលារៀនជំនាន់ថ្មីបានទេ ពីព្រោះការចុះឈ្មោះចូលរៀនក្នុងសាលា កម្មវិធីទាមទារយ៉ាងហោចណាស់សិស្សត្រូវមានមូលដ្ឋានគ្រឹះលើការចេះអានអក្សរ និងគិតលេខ។ អាស្រ័យដូចនេះហើយ បានជាការចុះឈ្មោះចូលរៀនក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី មិនអាចទទួលសិស្សទូលំទូលាយដូចសាលាសាធារណៈរបស់រដ្ឋផ្សេងទៀតឡើយ ។

ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានពិពណ៌នាខាងលើ សាលាជំនាន់ថ្មីត្រូវបានអនុញ្ញាតឱ្យបង្កើតការប្រឡងចូល ដែលផ្តោតលើការធានាថាសិស្សដែលដាក់ពាក្យសុំចូលរៀនអាចអានអក្សរ និងគិតលេខកម្រិតមូលដ្ឋានបាន ហើយការចុះឈ្មោះមិនលើសស្តង់ដាផលធៀបសិស្ស-ថ្នាក់រៀនទេ។ ការប្រឡងចូលគួរតែផ្តោតជាចម្បងលើ "ភាសាខ្មែរ" និង "គណិតវិទ្យា" ខណៈដែលអាចមានមុខវិជ្ជាបន្ថែម (ឧទាហរណ៍ សមត្ថភាពភាសាអង់គ្លេស វិទ្យាសាស្ត្រ។ល។) ជាមុខវិជ្ជាជម្រើស និងអាស្រ័យលើការសម្រេចចិត្តរបស់សាលា។

## ៣.៩ ការប្រើប្រាស់តេស្តក្រៅផ្លូវការ (Non-binding Test) ដើម្បីតាមដានលទ្ធផលសិក្សាសិស្ស

**ការប្រើប្រាស់តេស្តក្រៅផ្លូវការ៖** សាលារៀនជំនាន់ថ្មីលើកកម្ពស់ការគិតបែបស៊ីជម្រៅ និងជំរុញការអនុវត្តលើផ្នែកមួយចំនួនដែលមិនបានអនុវត្តពេញលេញក្នុងកម្មវិធីសិក្សាជាតិ។ ដូច្នេះ សាលាជំនាន់ថ្មីទាំងអស់ត្រូវធ្វើការជាមួយការិយាល័យកណ្តាលនៃកម្មវិធីសាលាជំនាន់ថ្មី ក្នុងការរៀបចំការធ្វើតេស្តមួយចំនួនដូចជា តេស្តគិតស៊ីជម្រៅ (Critical Thinking) ដើម្បីតាមដានកម្រិតនៃការគិតរបស់សិស្សក្នុងការដោះស្រាយកិច្ចការដែលមានលក្ខណៈស៊ីជម្រៅ ហើយដែលមិនមាននៅក្នុងកម្មវិធីសិក្សាធម្មតា។ លទ្ធផលនៃការធ្វើតេស្តក្រៅផ្លូវការនេះ គួរចែករំលែកតាមសាលាជំនាន់ថ្មីនីមួយៗ និងជាមួយក្រសួងអប់រំ យុវជន និងកីឡា (តាមរយៈរបាយការណ៍ប្រចាំឆ្នាំពីកម្មវិធីសាលាជំនាន់ថ្មី) ដែលផ្តល់ជាមតិត្រឡប់ទៅគ្រប់ភាគីពាក់ព័ន្ធ គ្រប់កម្រិតទាំងអស់ ដើម្បីពួកគេចាត់វិធានការសមស្របណាមួយ។

**ការគិតបែបស៊ីជម្រៅ៖** ការធ្វើតេស្តការគិតស៊ីជម្រៅត្រូវបានរៀបចំឡើងជាសំណួរតាមលំដាប់លំដោយ ដើម្បីតាមដានការអភិវឌ្ឍបំណិនការគិតបែបស៊ីជម្រៅរបស់សិស្សឱ្យបានកាន់តែប្រសើរឡើងដែលមិនមាននៅក្នុងកម្មវិធីសិក្សា។ តេស្តទាំងនេះ ផ្តោតទៅលើជំនាញផ្សេងៗ ដែលនាំទៅរកបំណិននៃការគិតបែបស៊ីជម្រៅដូចជា ៖

- ការកំណត់រកលំនាំគំរូ (ការទស្សន៍ទាយ)
- ការរៀបលំដាប់ព្រឹត្តការណ៍ ឬសាច់រឿង
- ការធ្វើចំណែកថ្នាក់
- បំណិនគិតបែបសទិសភាព
- បំណិនដោះស្រាយបញ្ហា
- ការវិភាគអត្ថបទ/ក្រាហ្វិក

តេស្តគិតស៊ីជម្រៅ ត្រូវអនុវត្តជាពិសេសសម្រាប់កម្រិតមធ្យមសិក្សា ហើយអនុវត្តដោយក្រុមការងារការិយាល័យកណ្តាលនៃកម្មវិធីសាលាជំនាន់ថ្មី។ តេស្តទាំងនេះត្រូវរៀបចំឡើងមានលក្ខណៈជាតេស្តក្រៅផ្លូវការ (ពោលគឺមិនមានផលប៉ះពាល់លើការសម្រេចចិត្តលើលទ្ធផលជាប់ ឬត្រួតថ្នាក់សិស្សទេ) ដូច្នេះ គ្រូបង្រៀនមិនមានអារម្មណ៍ថាមានសម្ពាធណាមួយក្នុងការបង្រៀនសម្រាប់ប្រឡងតេស្តប្រភេទនេះនោះទេ។

**តេស្តស្តង់ដាអន្តរជាតិលើសមត្ថភាពអំណាន និងលេខ៖** តេស្តក្រៅផ្លូវការនេះ ក៏មានអនុវត្តផងដែរសម្រាប់កម្រិតបឋមសិក្សាក្រោមទម្រង់ជាតេស្តអំណានថ្នាក់ដំបូង (EGRA) និងតេស្តគណិតវិទ្យាថ្នាក់ដំបូង (EGMA) ដើម្បីតាមដានការវិវត្តមូលដ្ឋានគ្រឹះក្នុងការអាន និងគិតលេខរបស់សិស្សក្នុងកម្រិតថ្នាក់ទី ១ ដល់ទី ៣ ។ តេស្តទាំងនេះប្រើប្រាស់គំរូអន្តរជាតិ មិនផ្តោតទៅលើកម្មវិធីសិក្សា តេស្តជាលក្ខណៈបុគ្គល និងប្រើប្រាស់កម្មវិធីសុសវែរមួយឈ្មោះ Tangerine [8] ដើម្បីធានាបាននូវកម្រិតនៃការជឿជាក់ទៅលើលទ្ធផលតេស្តខ្ពស់។ ការធ្វើតេស្ត EGRA និង EGMA ប្រើប្រាស់ស្តង់ដាអន្តរជាតិ

[8] https://www.tangerinecentral.org/about

នៃការអាន និងជំនាញគណិតវិទ្យា និងជួយសម្រួលដល់ការប្រៀបធៀបរវាងសាលាដើម្បីតាមដានលទ្ធផលសិក្សាសិស្ស។ ការធ្វើតេស្តទាំងនេះ ត្រូវបានអនុវត្តផ្ទាល់ដោយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) សហការជាមួយការិយាល័យកណ្តាលនៃកម្មវិធីសាលាជំនាន់ថ្មី។

**តេស្តកម្រិតអន្តរជាតិ៖** សាលាជំនាន់ថ្មីក៏បានចូលរួមក្នុងតេស្តកម្រិតអន្តរជាតិអំពីសមត្ថភាពប្រើប្រាស់ភាសាកំណើត គណិតវិទ្យា និងវិទ្យាសាស្ត្រផងដែរ។ ការធ្វើតេស្តនេះត្រូវបានអនុវត្តដោយផ្ទាល់ពីក្រសួងអប់រំ យុវជន និងកីឡា ហើយលទ្ធផលត្រូវកត់ត្រាដោយភ្នាក់ងារក្រៅប្រទេសក្នុងគោលបំណងប្រៀបធៀបជាអន្តរជាតិ។ ការិយាល័យកណ្តាលនៃកម្មវិធីសាលាជំនាន់ថ្មី មិនបានចូលរួមនៅក្នុងការធ្វើតេស្តនេះទេ។

## ៤. ទំនាក់ទំនងរវាងគោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្សរបស់NGS ជាមួយគោលនយោបាយ និងឯកសារសំខាន់ៗផ្សេងទៀត

គោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្សដែលបានរៀបរាប់នៅក្នុងឯកសារនេះមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយគោលនយោបាយ និងសៀវភៅណែនាំសំខាន់ៗមួយចំនួន ដែលត្រូវបានរៀបរាប់រួចមកហើយខាងលើ។ គោលនយោបាយ និងឯកសារទាំងនោះរួមមាន ៖

**គោលនយោបាយសាលារៀនជំនាន់ថ្មី** [9]**៖** ឯកសារគោលនយោបាយនេះបង្ហាញពីការប្តេជ្ញាចិត្តរបស់សាលាជំនាន់ថ្មីចំពោះនវានុវត្តន៍អប់រំ (ដែលធ្វើឱ្យមានឱកាសភាពការអនុវត្ត "ការបង្រៀនសម្រាប់តែការប្រឡង") តម្រូវការចាំបាច់ក្នុងការទទួលស្គាល់គុណភាពសាលារៀនជំនាន់ថ្មីដែលវាយតម្លៃប្រចាំឆ្នាំភ្ជាប់ទៅនឹងលក្ខណៈវិនិច្ឆ័យផលធៀបសិស្ស-ថ្នាក់រៀនក្នុងចំនួន ៣៦:១ ឬតិចជាងនេះ និងការប្រើប្រាស់កម្មវិធីសុសវែរសម្រាប់ការវាស់វែងបែបអេឡិចត្រូនិក។

**គោលការណ៍ណែនាំប្រតិបត្តិកម្មវិធីសាលារៀនជំនាន់ថ្មី** [10]**៖** គោលនយោបាយនេះបង្ហាញពីគោលការណ៍ណែនាំសម្រាប់ការរៀបចំការប្រឡងចូល និងការរក្សាស្តង់ដាសាលារៀនជំនាន់ថ្មី នីតិវិធីក្នុងការវាយតម្លៃទទួលស្គាល់គុណភាពសាលារៀនជំនាន់ថ្មី និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងដំណើរការអប់រំ រួមទាំងការវាស់វែងការសិក្សាបែបអេឡិចត្រូនិក។

**សៀវភៅបណ្តុះបណ្តាលស្តីពីការវាស់វែងការសិក្សាសិស្ស**[11]**៖** សៀវភៅនេះផ្តល់នូវការណែនាំដល់គ្រូបង្រៀនអំពីរបៀបបង្កើតតេស្តសំណេរ ដែលធានាបាននូវសុពលភាពខ្លឹមសារ និងសុពលភាពបំណិន ការប្រើប្រាស់ការវាយតម្លៃបែបដំណាក់ និងបែបសរុបដែលត្រូវនឹងគោលបំណងនៃការវាយតម្លៃនីមួយៗ ការដាក់ពិន្ទុតាមបែបលក្ខណៈវិនិច្ឆ័យ ការដាក់ពិន្ទុតាមខ្សែកោង និងការវិភាគតេស្ត ។

**សៀវភៅបណ្តុះបណ្តាលស្តីពីការសិក្សាបែបស្ថាបនានិយម**[12]**៖** សៀវភៅនេះផ្តល់នូវការណែនាំអំពីរបៀបវាស់វែងផលិតផលសិក្សាសិស្សតាមតាមគោលការណ៍ស្ថាបនានិយម។

**ក្របខណ្ឌគរុកោសល្យសតវត្សទី២១សម្រាប់ប្រទេសកម្ពុជា**[13]**៖** ឯកសារបច្ចេកទេសនេះពិភាក្សាអំពីគ្រោះថ្នាក់ដែលបង្កឡើងពីការអនុវត្ត "ការបង្រៀនសម្រាប់តែការប្រឡង" និងការជំរុញការប្រើប្រាស់វិធីបង្រៀនផ្តោតលើផលិតផលរបស់ស្ថាបនានិយម ជាជាងការប្រើប្រាស់ការវាស់វែងការសិក្សាសិស្សតាមបែបប្រពៃណីដូចជាតេស្តសំណេរជាដើម។ល។

[9] http://119.82.251.165:8080/xmlui/bitstream/handle/123456789/791/New%20Generation%20School%20Policy%20Guidelines.pdf?sequence=1

[10] http://www.kapekh.org/files/report_file/353-en.pdf

[11] Op. Cit. (cf. Footnote 4)

[12] Op. Cit. (cf. Footnote 6)

[13] http://www.kapekh.org/files/report_file/179-en.pdf

## ៥. តួនាទី និងទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធសាលារៀន ក្នុងការអនុវត្តគោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្ស

### ៥.១ ការផ្តោតទៅលើការអនុវត្តទូទៅ

សាលាជំនាន់ថ្មីប្រើគោលការណ៍គ្រប់គ្រងតាមសាលារៀន (SBM) ដែលផ្តល់អំណាចសម្រេចចិត្តទៅភាគីពាក់ព័ន្ធនៅតាមសាលារៀន រួមបញ្ចូលទាំងការវាស់វែងការសិក្សាសិស្សផងដែរ។ ហេតុផលនេះហើយ បានជាគេស្គាល់សាលារៀនជំនាន់ថ្មីទាំងអស់ថាជា "សាលារៀនរដ្ឋស្វយ័ត" ហើយគោលការណ៍ណែនាំដែលមានក្នុងឯកសារនេះ ផ្តោតសំខាន់ទៅលើការអនុវត្តរបស់ភាគីពាក់ព័ន្ធក្នុងកម្រិតសាលារៀន ដោយសាលាមានស្វ័យភាព និងភាពបត់បែនក្នុងការអនុវត្តតាមគោលការណ៍ណែនាំនេះទៅតាមតម្រូវការជាក់ស្តែងតាមសាលារៀននីមួយៗ ។

### ៥.២ ភាគីពាក់ព័ន្ធកម្រិតកណ្តាល

ទោះបីជាគោលការណ៍ណែនាំក្នុងគោលនយោបាយភាគច្រើន ផ្តោតទៅលើអ្នកពាក់ព័ន្ធក្នុងកម្រិតសាលារៀនក៏ពិតមែន តែក៏នៅមានផ្នែកខ្លះត្រូវការជាតុចូលពីកម្រិតកណ្តាលផងដែរ ពិសេសការិយាល័យកណ្តាលនៃកម្មវិធីសាលារៀនជំនាន់ថ្មី។

ទំនួលខុសត្រូវសំខាន់ៗមួយចំនួនរបស់អ្នកពាក់ព័ន្ធថ្នាក់កណ្តាលមានដូចខាងក្រោម៖

- **ការបង្កើត និងការអនុវត្តការធ្វើតេស្តក្រៅផ្លូវការ៖** តេស្តការគិតស៊ីជម្រៅ តេស្ត EGRA និង EGMA ជាទូទៅគឺជាការទទួលខុសត្រូវរបស់ការិយាល័យសាលារៀនជំនាន់ថ្មីថ្នាក់កណ្តាលក្នុងការបង្កើត ការអនុវត្ត និងការកត់ត្រាទិន្នន័យ។ ការផ្សព្វផ្សាយពីលទ្ធផលតេស្តទាំងនេះ ក៏ជាការទទួលខុសត្រូវរបស់ការិយាល័យកណ្តាលផងដែរ។
- **ប្រតិបត្តិការធនាគារសំណួរ៖** ការិយាល័យកណ្តាលនៃកម្មវិធីសាលារៀនជំនាន់ថ្មីក៏ទទួលខុសត្រូវក្នុងការរក្សាទុក និងរៀបចំរាល់សំណួរល្អៗ បានពីគ្រប់សាលារៀនជំនាន់ថ្មីទាំងអស់ដាក់ក្នុងធនាគារសំណួរផងដែរ។ ការិយាល័យកណ្តាលត្រូវធានាឱ្យបាននូវដំណើរការចូលទៅប្រើប្រាស់ធនាគារសំណួរនេះក្នុងវេបសាយសាលារៀនជំនាន់ថ្មី ពីគ្រប់ភាគីពាក់ព័ន្ធនឹងកម្មវិធីទាំងអស់។
- **ការកសាងសមត្ថភាពនៅក្នុងការវាស់វែងការសិក្សាសិស្ស៖** ការិយាល័យកណ្តាលនៃកម្មវិធីសាលាជំនាន់ថ្មី មានទំនួលខុសត្រូវទាំងស្រុងក្នុងការផ្តល់ការបណ្តុះបណ្តាលដល់ទាំងអ្នកគ្រប់គ្រងសាលា និងគ្រូបង្រៀនពីមូលដ្ឋានគ្រឹះនៃការវាស់វែងការសិក្សាសិស្សដោយប្រើប្រាស់សៀវភៅណែនាំ និងឯកសារទាំងអស់ ដែលបានពិភាក្សានៅក្នុងផ្នែកទី ៤ ខាងលើ។
- **ការធ្វើលទ្ធកម្មសុសវែរសម្រាប់ការធ្វើតេស្តអេឡិចត្រូនិក៖** ការធ្វើតេស្តអេឡិចត្រូនិកតម្រូវឱ្យមានកម្មវិធីសុសវែរ និងវេទិកានៃការប្រឡងជាក់លាក់មួយ។ ការធ្វើលទ្ធកម្មសុសវែរនេះ ជា

បន្ទុករបស់ការិយាល័យកណ្ដាលកម្មវិធីសាលារៀនជំនាន់ថ្មី ព្រោះកម្មវិធីមានលទ្ធភាពច្រើនក្នុងការរក្សាអ្នកផ្ដល់សេវាសុសវែរ និងចចារថវិកាចំណាយទៅលើការប្រើប្រាស់កម្មវិធីពេលមានបរិមាណប្រើប្រាស់ខ្ពស់។ បន្ទាប់ពីលទ្ធកម្មត្រូវបានបញ្ចប់ ការិយាល័យកណ្ដាលរៀបចំឱ្យមានការប្រើប្រាស់កម្មវិធីសុសវែរនេះ ទៅគ្រប់សាលារៀនក្នុងប្រព័ន្ធសាលារៀនជំនាន់ថ្មីទាំងអស់។

## ៥.៣ អ្នកពាក់ព័ន្ធកម្រិតសាលារៀន

ភាគីពាក់ព័ន្ធកម្រិតសាលារៀនមានទំនួលខុសត្រូវចម្បងសម្រាប់ការអនុវត្តគោលការណ៍ណែនាំដែលមានចែងក្នុងឯកសារនេះ។ ខាងក្រោមនេះ ជាការពិពណ៌នាតួនាទី និងភារកិច្ចរបស់ភាគីពាក់ព័ន្ធកម្រិតសាលារៀន៖

- **នាយកសាលា៖** នាយកសាលាដើរតួនាទីសំខាន់ណាស់ក្នុងការរៀបចំការប្រឡងវាស់វែងបែបសរុប ដូចជាការប្រឡងឆមាស និងការប្រឡងបញ្ចប់ឆ្នាំជាដើម។ នេះរាប់បញ្ចូលទាំងការរៀបចំតេស្ត(ដោយប្រើប្រាស់តារាងផែនការតេស្ត និងសំណួរបានពីគ្រូបង្រៀន) ការបង្កើតតេស្ត ការគ្រប់គ្រងដំណើរការប្រឡង ការកត់ត្រាទិន្នន័យលទ្ធផល និងការផ្សព្វផ្សាយលទ្ធផលតេស្តទៅគ្រប់ភាគីពាក់ព័ន្ធ។ នាយកសាលាក៏មានតួនាទីផងដែរក្នុងការធានាថាគ្រូបង្រៀនប្រើប្រាស់ការវាស់វែងការសិក្សាផ្សេងៗទៀតទាំងការវាស់វែងការសិក្សាបែបដំណាក់ និងបែបសរុបក្នុងដំណើរការបង្រៀន និងរៀន។ ជាចុងក្រោយ នាយកសាលាដើរតួជាអ្នករៀបចំកម្មវិធីជំនួបផ្សព្វផ្សាយលទ្ធផលសិក្សាសិស្សជាមួយអាណាព្យាបាលសិស្ស និងធ្វើជាអន្តរការីរវាងគ្រូបង្រៀន និងអាណាព្យាបាលសិស្សអំឡុងពេលនោះ។
- **គ្រូបង្រៀន៖** គ្រូបង្រៀនមានតួនាទីសំខាន់បំផុតក្នុងការអនុវត្តគោលនយោបាយស្ដីពីការវាស់វែងការសិក្សាសិស្ស ដោយសារពួកគេជាអ្នកប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយសិស្ស និងជាអ្នកធ្វើផែនការវាស់វែងបែបដំណាក់ និងការសម្រេចចិត្តឱ្យឡើងថ្នាក់បែបសរុប។ ដូចនេះហើយ ពួកគេទទួលខុសត្រូវទាំងស្រុងចំពោះការវាស់វែងការសិក្សាបែបដំណាក់នៅក្នុងថ្នាក់រៀន និងការរៀបចំការធ្វើតេស្តប្រចាំខែ ឬការវាស់វែងដែលមិនប្រើតេស្តផ្សេងទៀត ដែលអាចជំនួសការធ្វើតេស្តប្រចាំខែ។ គ្រូម្នាក់ៗកំណត់ប្រភេទនៃឧបករណ៍វាស់វែងដែលត្រូវប្រើជាមួយសិស្ស ហើយឧបករណ៍ទាំងនេះ គួរតែមានតុល្យភាពរវាងការវាស់វែងដោយប្រើតេស្ត និងមិនប្រើតេស្ត។ គ្រូបង្រៀនត្រូវកត់ត្រាលទ្ធផលសិក្សាសិស្ស និងធ្វើរបាយការណ៍ជូនទៅនាយកសាលាដើម្បីធ្វើការផ្សព្វផ្សាយជាមួយអាណាព្យាបាល។ គ្រូបង្រៀនគួរមានក្រុមមុខវិជ្ជា ឬក្រុមតាមកម្រិតថ្នាក់ដែលដឹកនាំដោយប្រធានក្រុមបច្ចេកទេស ឬប្រធានក្រុមតាមកម្រិតថ្នាក់ ដើម្បីងាយស្រួលក្នុងការរៀបចំតេស្តដែលប្រើទូទាំងសាលា ឬការវាស់វែងការសិក្សាផ្សេងៗទៀត។

- **គ្រូប្រឹក្សាគរុកោសល្យតាមសាលា៖** គ្រូប្រឹក្សាគរុកោសល្យផ្តល់បច្ចេកទេស និងគរុកោសល្យដល់គ្រូបង្រៀនក្នុងការបង្កើតឧបករណ៍វាស់វែងការសិក្សា (ទាំងការវាស់វែងដោយប្រើតេស្ត និងមិនប្រើតេស្ត) តាមគោលការណ៍ស្តង់ដានៃការវាស់វែងការសិក្សាសិស្ស។ លើសពីនេះទៀត គ្រូប្រឹក្សាគរុកោសល្យត្រូវផ្តល់ដំបូន្មានគរុកោសល្យដល់គ្រូបង្រៀនផងដែរពីកម្រិតនៃការយល់ដឹងសិស្ស (ឧទាហរណ៍ ផ្អែកលើលទ្ធផលតេស្ត EGRA/EGMA និងទិន្នន័យវាស់វែងផ្សេងទៀត) និងវិធានការសមស្របសម្រាប់ការកែលម្អការបង្រៀន។ គ្រូប្រឹក្សាគរុកោសល្យត្រូវរក្សាទំនាក់ទំនងល្អជាមួយគ្រូបង្រៀន និងត្រូវរក្សាការសម្ងាត់អំពីព័ត៌មានគរុកោសល្យមួយចំនួន ដើម្បីកុំឱ្យគ្រូមានសម្ពាធក្នុងការអនុវត្ត (ឧ.បង្រៀនដើម្បីតែធ្វើតេស្ត)។
- **មាតាបិតាសិស្ស៖** មាតាបិតា មានតួនាទីជួយផ្តល់មតិត្រឡប់ទៅគ្រូបង្រៀនអំពីរបាយការណ៍ការអនុវត្តសិស្សដែលបានទទួលពីសាលា ចូលរួមកិច្ចប្រជុំជាមួយសាលាដើម្បីយល់ដឹងឱ្យកាន់តែស៊ីជម្រៅពីក្របខ័ណ្ឌ និងគោលនយោបាយវាស់វែងការសិក្សាសិស្ស និងជួបពិភាក្សាជាមួយគ្រូបង្រៀនពីមធ្យោបាយ ដែលពួកគាត់អាចជួយការសិក្សារបស់កូននៅផ្ទះឱ្យបានប្រសើរជាងមុន ៕